**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខ..២០..ឯ.ក....វវស

# ប្រកាស

# ស្តីពី

# ការបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាព ដែលរំលោភបំពានលើ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

## រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ប្រកាសឱ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

## <u>សម្រេច</u>

**<u>ប្រការ</u> ១.-**

**ស្នាដៃ** ជាផលិតផលខាងវិស័យ អក្សរសាស្ត្រ វិទ្យាសាស្ត្រ សិល្បៈ ឬតូរ្យតន្ត្រី កើតចេញពីការច្នៃប្រឌិតបង្កើតឡើងដោយគំនិតប្រាជ្ញា ឬមនោសញ្ចេតនា ។

**<u>ប្រការ</u> ២.-**

**អ្នកនិពន្ធ** ជាជនដែលបង្កើតបានស្នាដៃ ។

និងផ្សព្វផ្សាយពាណិជ្ជកម្ម ផ្សេងៗ សិទ្ធិអ្នកសំដែង សិទ្ធិផលិតករហ្វូណូក្រាម និងសិទ្ធិអង្គភាពផ្សព្វផ្សាយ ។

**អង្គភាពផ្សព្វផ្សាយ** គឺស្ថានីយវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប ឬផ្កាយរណប ។

**ប្រការ ៣.-**

ស្នាដៃទាំងឡាយដែលត្រូវទទួលបានការការពារក្រោមច្បាប់នេះមាន :

ក-សៀវភៅអានគ្រប់ប្រភេទ ឬឯកសារផ្សេងៗទៀតស្តីពីអក្សរសាស្ត្រ សិល្បៈ វិទ្យាសាស្ត្រ និងការអប់រំ ។

ខ-អត្ថបទបាឋកថា សង្កថា ធម្មទេសនា ការការពារខ្លួនដោយនិយាយ ឬដោយសរសេរ និងស្នាដៃផ្សេងៗទៀត ដែលមានប្រភេទដូចគ្នា ។

គ- ស្នាដៃនាដកម្ម ឬនាដកម្ម-តូរ្យតន្ត្រី ។

ឃ- ស្នាដៃរបាំសម័យ ឬយកលំនាំតាមស្នាដៃបុរាណ ឬប្រពៃណី ។

ង- ការសម្តែងសៀក និងការសម្តែងកាយវិការ ។

ច- ការតែងបទភ្លេងដោយមាន ឬគ្មានទំនុកច្រៀង ។

ឆ- ស្នាដៃសោតទស្សន៍ ។

ជ- ស្នាដៃជាផ្ទាំងគំនូរ ផ្ទាំងចម្លាក់ រូបចម្លាក់ ឬស្នាដៃផ្សេងៗទៀតខាងសិល្បៈសូនរូប ឬសិល្បៈអនុវត្ត ។

ឈ- ស្នាដៃថតរូប និងស្នាដៃទាំងឡាយដែលសម្រេចបានដោយសារមានជំនួយបច្ចេកទេសដូចគ្នា នឹងការថតរូប ។

ញ-ស្នាដៃស្ថាបត្យកម្ម ។

ដ-ផែនទី ប្លង់ គំនូសវាស ឬស្នាដៃស្តែងចេញជារូប ដែលទាក់ទងនឹងភូមិសាស្ត្រ ឋានលេខា ឬវិទ្យាសាស្ត្រនានា ។

ឋ-កម្មវិធីកុំព្យូទ័រ និងគម្រោងឯកសារសមោធាន ដែលទាក់ទងទៅនឹងកម្មវិធីទាំងនោះ ។

ឌ- ផលិតផលផ្នែកសិប្បកម្ម តម្បាញ ឬម៉ូតសម្លៀកបំពាក់ផ្សេងៗ ។

**ប្រការ ៤.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានបង្កើតស្នាដៃដូចមានចែងក្នុងប្រការ៣ខាងលើ មានឈ្មោះថាជាម្ចាស់កម្មសិទ្ធិ លើស្នាដៃ ហើយទទួលបាននូវសិទ្ធិធ្វើអាជីវកម្ម និងសិទ្ធិការពារលើស្នាដៃរបស់ខ្លួន ។

**ប្រការ ៥.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលនូវសិទ្ធិស្របច្បាប់លើស្នាដៃដូចមានចែងក្នុងប្រការ៣ខាងលើ មានឈ្មោះថាជាម្ចាស់កម្មសិទ្ធិលើស្នាដៃហើយទទួលបាននូវសិទ្ធិធ្វើអាជីវកម្ម និងសិទ្ធិការពារលើស្នាដៃនោះ ។

**ប្រការ ៦.-**

ត្រូវបញ្ជប់ជាបទនាន់នូវសកម្មភាពដូចតទៅ ÷

ក-ការផលិត ឬការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈនូវស្នាដៃដោយគ្មានការអនុញ្ញាតពីម្ចាស់

ខ-ការក្លែងបន្លំ ក្នុងការផលិត ឬការផលិតឡើងវិញនូវស្នាដៃដែលរំលោភបំពានលើម្ចាស់កម្មសិទ្ធិ ។

គ-ការនាំចូលនូវផលិតផលនៃស្នាដៃពីបរទេសដើម្បីធ្វើអាជីវកម្ម ឬបង្កើតស្នាដៃបន្តដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ។

ឃ-ការនាំចេញនូវស្នាដៃ ដើម្បីធ្វើអាជីវកម្មដោយគ្មានការយល់ព្រមពីម្ចាស់កម្មសិទ្ធិ ។

**<u>ប្រការ</u> ៧.-**

ចាប់ពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០៣ រាល់អំពើល្មើសដែលរំលោភបំពានលើសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ។

**<u>ប្រការ</u> ៨.-**

ខុទ្ទកាល័យ អធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ គ្រប់អង្គភាពចំណុះក្រសួង មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈគ្រប់ខេត្តក្រុង ទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិ.ា ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

នរោត្តម - បុប្ផាទេវី

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងពត៌មាន
- ក្រសួងឧស្សាហកម្ម
- ក្រសួងយុត្តិធម៌
- គ្រប់ក្រសួង

"<u>ដើម្បីជូនជ្រាបជាព័ត៌មាន</u>"
- ដូចប្រការ៨ "ដើម្បីអនុវត្ត"
- ឯកសារកាលប្បវត្តិ